កិច្ចពិគ្រោះយោបល់ថ្នាក់ជាតិ

ស្តីអំពី "**ការអភិវឌ្ឍគោលនយោបាយ និងក្របខណ្ឌច្បាប់ពាក់ព័ន្ធនឹងអង្គការសង្គមស៊ីវិល**"

**ថ្ងៃ ២ រោច ខែបឋមាសាឍ ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២**
**ត្រូវនឹងថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០១៨**

សុន្ទរកថារបស់លោក **សឿង សារឿន**

នាយកប្រតិបត្តិអង្គការគណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា (CCC)

---

- សូមគោរព! **ឯកឧត្តម ប៊ុន ហ៊ុន** អនុរដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាតំណាងដ៏ខ្ពង់ខ្ពស់របស់សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ
- សូមគោរព! **លោក ហ្វ្រេង វីយោលត៍** (Frank Viault) អគ្គទីប្រឹក្សា-ប្រធានផ្នែកសហប្រតិបត្តិការ នៃប្រតិភូនៃសហភាពអឺរ៉ុបប្រចាំព្រះរាជាណាចក្រកម្ពុជា
- លោកជំទាវ ឯកឧត្តម លោកស្រី លោក អ្នកនាងកញ្ញា ដែលជាតំណាងក្រសួងមហាផ្ទៃ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងផែនការ ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ និងស្ថាប័ននានារបស់រដ្ឋាភិបាល អង្គទូត តំណាងអង្គការសហប្រជាជាតិ ដៃគូអភិវឌ្ឍ អង្គការ សមាគមមិនរដ្ឋាភិបាលជាតិ និងអន្តរជាតិ អង្គការសហគមមូលដ្ឋាន អ្នកសារព័ត៌មាន បងប្អូន ជាភ្ញៀវជាតិ និងអន្តរជាតិ និង អង្គវេទិកាទាំងមូល ជាទីគោរព និងរាប់អាន!

ក្នុងនាមគណៈកម្មាធិការប្រតិបត្តិ ថ្នាក់គ្រប់គ្រង និងបុគ្គលិក នៃគណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា (CCC) និងក្នុងនាមខ្លួនខ្ញុំផ្ទាល់ ខ្ញុំមានមហាកិត្តិយស និងសេចក្តីសោមនស្សរីករាយ និងសូមស្វាគមន៍យ៉ាងកក់ក្តៅ និងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះគណៈអធិបតី លោកជំទាវ ឯកឧត្តម លោកស្រី លោក អ្នកនាងកញ្ញា បងប្អូន ជាភ្ញៀវជាតិ និងអន្តរជាតិដែលបានចំណាយពេលវេលាដ៏មានតម្លៃចូលរួមជាគណៈអធិបតី ជាវាគ្មិន និងជាអ្នកចូលរួម នៅក្នុងកិច្ចពិគ្រោះយោបល់ថ្នាក់ជាតិស្តីអំពី "**ការអភិវឌ្ឍគោលនយោបាយ និងក្របខណ្ឌច្បាប់ពាក់ព័ន្ធនឹងអង្គការសង្គមស៊ីវិល**" ដែលជារៀបចំដោយ គណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា (CCC) និងគាំទ្រមូលនិធិដោយ សហគមន៍អឺរ៉ុប អង្គការ ប្រេដហ្វដឺវើល អុកស្វាម និងម្ចាស់មូលនិធិនានារបស់អង្គការ CCC នាថ្ងៃនេះ។

អង្គការ CCC ជាអង្គការសមាជិកភាពដែលមានអង្គការ សមាគមមិនមែនរដ្ឋាភិបាលក្នុងស្រុក និងបរទេស ជាង១៧០ ជាសមាជិក និងមានបណ្ដាញអង្គការ សមាគមមិនមែនរដ្ឋាភិបាលថ្នាក់ជាតិ និងតាមបណ្ដាខេត្តជិត២០ ព្រមទាំងអង្គការ សមាគមមិនមែនរដ្ឋាភិបាល និងអង្គការសហគមន៍មូលដ្ឋានជាង៥០០០ ជាដៃគូ និងអ្នកទទួលផលផ្ទាល់ពីប្រតិបត្តិការរបស់ អង្គការ CCC។ អង្គការCCC មានបេសកកម្ម ធ្វើការងារជាដៃគូដើម្បីលើកកំពស់អភិបាលកិច្ចល្អ បរិយាកាសអំណោយផល និងនិរន្តរភាពរបស់អង្គការស៊ីវិលនៅកម្ពុជា ដើម្បីឆ្លើយតបទៅនឹងបញ្ហាប្រឈមនានា ឆ្ពោះទៅការអភិវឌ្ឍប្រទេសកម្ពុជាប្រកបដោយនិរន្តរភាព និងប្រជាធិបតេយ្យ។

ខ្ញុំសូមជំរាបជូន ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី និងអង្គពិធីទាំងមូលឲ្យបានជ្រាបថា ចាប់តាំងពីឆ្នាំ១៩៩០ និងជាពិសេសក្រោយកិច្ចព្រមព្រៀងទីក្រុងប៉ារីសស្ដីពីកម្ពុជាឆ្នាំ១៩៩១ អង្គការCCC សមាជិករបស់ខ្លួន និងសង្គមស៊ីវិលទាំងមូលបានដើរតួនាទីយ៉ាងសំខាន់ក្នុងការចូលរួមចំណែកអភិវឌ្ឍប្រទេសកម្ពុជាស្ទើរលើគ្រប់វិស័យ។ តួយ៉ាងការសិក្សារួមមួយស្ដីអំពីការចូលរួមរបស់សង្គមស៊ីវិលនៅក្នុងការអភិវឌ្ឍប្រទេសកម្ពុជា ដែលបានធ្វើឡើងជាមួយអង្គការសង្គមស៊ីវិលជិត ២០០០ (ពីរពាន់) អង្គការ កាលពីឆ្នាំ ២០១២ បានបង្ហាញថា សង្គមស៊ីវិល បានចំណាយថវិកាសរុបប្រមាណជាង ៦០០ ទៅ ៧០០ លានដុល្លាក្នុងមួយឆ្នាំៗ សម្រាប់ចូលរួមក្នុងការអភិវឌ្ឍប្រទេសកម្ពុជា និងផ្ដល់ផលប្រយោជន៍ដល់អ្នកទទួលផលដោយផ្ទាល់ និងដោយប្រយោលជិត ១២លាននាក់[1]។ សមិទ្ធិផលសំខាន់ៗ និងវឌ្ឍនភាពជាច្រើន ដែលកើតឡើងតាមរយៈភាពជាដៃគូរវាងសង្គមស៊ីវិលជាមួយរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍនានា ដោយផ្ទាល់ក្ដី និងប្រយោលក្ដី មានដូចជា៖ ១) ការឆ្លើយតបនឹងគ្រោះមហន្តរាយធម្មជាតិ និងជំងឺរាតត្បាតនានា ពិសេសការកាត់បន្ថយការរីករាលដាលមេរោគអេដស៍ ២) ការចូលរួមពង្រឹងគុណភាពសេវានានា រួមមាន សេវាអប់រំ សុខាភិបាល ការអភិវឌ្ឍជនបទរួមទាំងអនាម័យទូទៅ និងគមនាគមន៍ជនបទ, ៣) ការលើកកំពស់ការយល់ដឹងអំពីប្រជាធិបតេយ្យ សិទ្ធិមនុស្ស សិទ្ធិស្ត្រី សិទ្ធិកុមារ សិទ្ធិជនពិការ សិទ្ធិជនជាតិដើម និងសមភាពយេនឌ័រ, ៤) ការអភិវឌ្ឍធនធានមនុស្ស ជាពិសេសយុវជន និងកុមារដើម្បីឲ្យក្លាយជាប្រជាពលរដ្ឋសកម្ម និងអាជ្ញាធរ ព្រមទាំងមន្ត្រីរដ្ឋាភិបាលឲ្យក្លាយជាមន្ត្រីដែលមានការទទួលខុសត្រូវខ្ពស់, ៥) ការលើកកម្ពស់ជីវភាពរស់នៅ និងមុខរបរ, និង ៦) ការលើកកំពស់ការអភិរក្សធនធានធម្មជាតិ និងការប្រយុទ្ធប្រឆាំងនឹងបំរែបំរួលអាកាសធាតុ និង វិស័យជាអាទិភាពជាច្រើនទៀត ស្របតាមគោលនយោបាយអភិវឌ្ឍន៍ជាតិ និង ថ្នាក់ក្រោមជាតិរបស់រាជរដ្ឋាភិបាល។

**ឯកឧត្តម លោកជំទាវ អស់លោក លោកស្រីជាទីគោរព!**

បើទោះបីជា**អង្គការសង្គមស៊ីវិល** បានបំពេញតួនាទី និងការចូលរួមក្នុងការអភិវឌ្ឍប្រទេសបានល្អប្រសើរគួរឲ្យកត់សម្គាល់ជិតបីទសវត្សន៍កន្លងមកក្ដី ក៏ប៉ុន្តែប៉ុន្មានឆ្នាំចុងក្រោយនេះ ជាពិសេសក្រោយច្បាប់ស្ដីអំពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាលត្រូវបានអនុម័ត និងចូលជាធរមាន សង្គមស៊ីវិលបានជួបប្រទះនូវបញ្ហា

[1] CSO Contribution to the Development of Cambodia (2012)

ប្រឈមសំខាន់ៗ ក៏ដូចជាមានក្ដីបារម្ភមួយចំនួន ដែលពាក់ព័ន្ធដល់ការបំពេញតួនាទីរបស់ខ្លួនឲ្យមានប្រសិទ្ធភាព និងនិរន្តរភាព។ បញ្ហាទាំងនោះរួមមាន៖

1. **នីតិវិធីរដ្ឋបាលស្មុគស្មាញ:** ការតម្រូវឲ្យមានការអនុញ្ញាតពីអាជ្ញាធរមូលដ្ឋាននូវរាល់ពេលអង្គការសង្គមស៊ីវិលធ្វើសកម្មភាពរបស់ខ្លួន បើទោះបីជាសកម្មភាពទាំងនោះសុទ្ធតែធ្លាប់បានអនុវត្តនៅក្នុងមូលដ្ឋានរួចមកហើយក្ដី។ ការជូនដំណឹងអំពីការផ្លាស់ប្ដូរថ្នាក់ដឹកនាំ និងស្ថានភាពពាក់ព័ន្ធ តែតម្រូវឲ្យមានការទទួលស្គាល់ ហើយអង្គការមួយចំនួនបានចំណាយថវិកាយ៉ាងច្រើនដើម្បីឆ្លើយតបទៅនឹងតម្រូវការទាំងនេះ។ ការដាក់ជូនរបាយការណ៍ ដែលតម្រូវដោយច្បាប់គឺ១ឆ្នាំម្ដង តែជាក់ស្ដែងអាជ្ញាធរខ្លះតម្រូវឲ្យអង្គការមួយចំនួនរាយការណ៍ជារៀងរាល់ខែ។
2. **ឥទ្ធិពលជាអវិជ្ជមានពីការផ្លាស់ប្ដូរបរិយាកាសនយោបាយ:** អង្គការសង្គមស៊ីវិលមួយចំនួនត្រូវបានគេភ្ជាប់ទៅនឹងចលនានយោបាយ គណបក្សនយោបាយ ឬចូលរួមក្នុងបដិវត្តន៍ពណ៌ដែលមិនធ្លាប់មាននៅកម្ពុជាជាដើម។ ហេតុផលនេះបាន និងកំពុងជះឥទ្ធិពលអវិជ្ជមាន ទាំងដោយផ្ទាល់ និងប្រយោលដល់អង្គការសង្គមស៊ីវិលស្ទើរគ្រប់វិស័យពាក់ព័ន្ធជាមួយនឹងការអនុវត្តសិទ្ធិ និងសេរីភាពនៃការបញ្ចេញមតិ និងការជួបជុំរបស់ពួកគេ។
3. **ក្របខណ្ឌគតិយុត្តិដែលពាក់ព័ន្ធនឹងអង្គការសង្គមស៊ីវិល:** ការអនុវត្តយ៉ាងគំហុក ខណៈសមត្ថភាពឆ្លើយតបរបស់អង្គការសង្គមស៊ីវិលនៅមានកម្រិត បញ្ញត្តិនៃច្បាប់ បទបញ្ជា ឬសេចក្ដីណែនាំមួយចំនួនមិនមានសង្គត់ភាព និងស្តង់ដាររួមនៃក្របខណ្ឌគតិយុត្តិ និងខ្វះយន្តការគាំទ្រគ្រប់កម្រិត ព្រមទាំងការឆ្លើយតបមិនទាន់ពេលវេលា ដែលធ្វើឲ្យពួកគេមិនអាចបំពេញកាតព្វកិច្ច និងឆ្លើយតបបានសមស្រប។
4. **ស្ថានភាពហិរញ្ញប្បទានសំរាប់អង្គការសង្គមស៊ីវិលកំពុងថយចុះជាលំដាប់:** ស្របពេលដែលប្រទេសកម្ពុជាបានក្លាយជាប្រទេសដែលមានប្រាក់ចំណូលមធ្យមកម្រិតទាប (Low Middle Income Country) ស្ថានភាពជំនួយពីសហគមន៍អន្តរជាតិ ជាពិសេសតាមរយៈជំនួយអភិវឌ្ឍផ្លូវការ (Official Development Assistance) មានការធ្លាក់ចុះ ដែលធ្វើអោយមានការប៉ះពាល់ជាសារវ័ន្តទៅដល់ហិរញ្ញប្បទានសម្រាប់អង្គការសង្គមស៊ីវិល ស្របពេលដែលភាពជាដៃគូរវាងសង្គមស៊ីវិលជាមួយតួអង្គអភិវឌ្ឍផ្សេងៗទៀត រួមទាំងវិស័យឯកជន នៅពុំទាន់មានភាពល្អប្រសើរនៅឡើយ។
5. **ផែនការគោលដៅអភិវឌ្ឍប្រកបដោយចីរភាពឆ្នាំ២០៣០៖** បានជំរុញ និងទាមទារឲ្យសង្គមស៊ីវិលបង្កើនសមត្ថភាព ប្រសិទ្ធិភាព ធនធាន និងរបៀបធ្វើការងារកាន់តែមានភាពនិរានុវត្ត និងប្រទាក់ក្រឡា។

ថ្ងៃនេះខ្ញុំបាទក៏សូមធ្វើការកត់សម្គាល់នូវសំណើមួយចំនួន ដែលបានទទួលពីការពិគ្រោះយោបល់ជាមួយអង្គការសង្គមស៊ីវិលមួយចំនួនធំនៅកំរិតថ្នាក់ជាតិ និងក្រោមជាតិ ហើយសំណូមពរមួយចំនួនក៏ត្រូវបានលើកឡើងនៅក្នុងវេទិកា **ភាពជាដៃគូរវាងរដ្ឋាភិបាល និងសង្គមស៊ីវិល** កាលពីថ្ងៃទី ២១ ខែមិថុនា កន្លងទៅនេះ។

<u>សំណើសុំសំខាន់ៗពីសង្គមស៊ីវិលសម្រាប់រាជរដ្ឋាភិបាល</u>៖

- គួរមានក្រុមការងារបច្ចេកទេសចម្រុះដែលមានតំណាងពីក្រសួងពាក់ព័ន្ធ និងអង្គការសង្គមស៊ីវិល ដើម្បីសន្ទនាពិភាក្សា និងរកដំណោះស្រាយ ល្អបំផុតចំពោះបញ្ហាពាក់ព័ន្ធនឹងច្បាប់ស្តីពីសមាគមន៍ និងអង្គការមិនមែនរដ្ឋាភិបាល បទបញ្ជា និងច្បាប់នានាដែលពាក់ព័ន្ធនឹងអង្គការសង្គមស៊ីវិល។
- អង្គការសង្គមស៊ីវិល និងរដ្ឋាភិបាលយ៉ាងហោចណាស់គួរជួបប្រជុំប្រចាំឆ្នាំ ដើម្បីឆ្លុះបញ្ចាំងពីសមិទ្ធិផលលើកកំពស់ភាពជាដៃគូ និងឆ្លុះបញ្ចាំងពីការអនុវត្តគោលនយោបាយនានា និងច្បាប់ស្តីពីសមាគមន៍ និងអង្គការមិនមែនរដ្ឋាភិបាល និងច្បាប់ពាក់ព័ន្ធផ្សេងៗទៀត។
- ពង្រឹងយន្តការដែលមានស្រាប់ឲ្យមានគុណភាព និង ប្រសិទ្ធភាព ដូចជាក្រុមការងារបច្ចេកទេស (TWG) ក្របខណ្ឌគណនេយ្យភាពសង្គម (ISAF) និង បង្កើតយន្តការភាពជាដៃគូពហុភាគី (រដ្ឋាភិបាល សង្គមស៊ីវិល វិស័យឯកជន និងដៃគូអភិវឌ្ឍ) ស្របតាមគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព (SDG) និង ភាពជាដៃគូជាមួយរដ្ឋាភិបាលបើកទូលាយ (OGP) ដែលនឹងជំរុញឲ្យមានជំនឿទុកចិត្តចំពោះគ្នា និងកិច្ចសហប្រតិបត្តិការយ៉ាងស្អិតរមួតដើម្បី**ការអភិវឌ្ឍប្រកបដោយប្រជាធិបតេយ្យ និងចីរភាព**។
- រាជរដ្ឋាភិបាលពិចារណានិរាករណ៍ ឬកែសម្រួលនូវប្រកាសអន្តរក្រសួងលេខ ១៧០ ប្រក.អន្តរក្រ ចុះថ្ងៃទី ២៨ ខែឧសភា ឆ្នាំ២០១៨ ដោយមូលហេតុថា ខ្លឹមសារនៃប្រកាសនេះមានលក្ខណៈទូលាយ ទូទៅ និងអាចមានផលវិបាកជាអវិជ្ជមានក្នុងការអនុវត្ត ជាពិសេសចំពោះការបកស្រាយ។ រាជរដ្ឋាភិបាលគួរពន្លឿនការអនុម័តច្បាប់ស្តីអំពីសិទ្ធិទទួលបានព័ត៌មាន និង ធានានូវសិទ្ធិសេរីភាពជាមូលដ្ឋានរបស់ប្រជាពលរដ្ឋក្នុងការសម្រេចចិត្តលើវិស័យនយោបាយ សេដ្ឋកិច្ចសង្គមជាដើម។
- ក្រសួងមហាផ្ទៃ និងក្រសួងពាក់ព័ន្ធនានាគួររៀបចំឲ្យមានការផ្សព្វផ្សាយ បណ្តុះបណ្តាល ឲ្យបានទូលាយដើម្បីលើកកម្ពស់ការយល់ដឹងអំពីច្បាប់ ការវិវឌ្ឍនៃច្បាប់ ក៏ដូចជានីតិវិធីនានាដែលពាក់ព័ន្ធនឹងការអនុវត្តន៍នៃច្បាប់ និងបទប្បញ្ញត្តិទាំងនោះ ព្រមទាំងរៀបចំឲ្យមានជនបង្គោល ឬមន្ត្រីទំនាក់ទំនងតាមឯកទេសច្បាស់លាស់ សម្រាប់ការផ្តល់ប្រឹក្សាយោបល់ និងឆ្លើយតបនូវរាល់កង្វល់ដែលពាក់ព័ន្ធនឹងការអនុវត្តច្បាប់ និងបទប្បញ្ញត្តិទាំងនោះ។
- ច្បាប់ស្តីពីគណនេយ្យ និងសវនកម្ម គួរត្រូវបានពន្យាពេលសំរាប់ការអនុវត្តចំពោះអង្គការសង្គមស៊ីវិល ដោយហេតុថា សង្គមស៊ីវិលពុំទាន់យល់ និងត្រៀមខ្លួនរួចរាល់ ក្នុងការរៀបចំ និងអនុវត្តប្រព័ន្ធស្តង់ដាគណនេយ្យហិរញ្ញវត្ថុទៅតាមតម្រូវការរបស់រាជរដ្ឋាភិបាល។ កន្លងមកប្រព័ន្ធគណនេយ្យហិរញ្ញវត្ថុរបស់

អង្គការសង្គមស៊ីវិលតែងតែមានការត្រួតពិនិត្យ និងសវនកម្មពីសំណាក់ម្ចាស់ជំនួយ ទោះយ៉ាងណាអង្គការសង្គមស៊ីវិលមួយភាគធំនៅតែត្រូវការឱ្យមាន ការគាំទ្រនិងពង្រឹងសមត្ថភាព និងធនធានសមស្របបន្ថែមទៀត មុនពេលដែលពួកគាត់អាចរៀបចំប្រព័ន្ធគណនេយ្យហិរញ្ញវត្ថុផ្ទៃក្នុងស្របទៅតាមការតម្រូវរបស់រដ្ឋាភិបាល។

- រាជរដ្ឋាភិបាល ជាពិសេសក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងអគ្គនាយកដ្ឋានពន្ធដារគួរផ្តល់ការលើកទឹកចិត្ត និងមានយន្តការណាមួយជួយសម្រួលដល់អង្គការ សមាគមទាំងឡាយណាដែលបានចុះបញ្ជីជាមួយក្រសួងមានសមត្ថកិច្ច ហើយមិនទាន់បានចុះបញ្ជីសារពើពន្ធ ព្រមទាំងមិនទាន់បានអនុលោមកាតព្វកិច្ចបង់ពន្ធត្រឹមត្រូវ ដោយផ្តល់ឲ្យពួកគេមានឱកាសបានបំពេញកាតព្វកិច្ចត្រឹមត្រូវស្របតាមច្បាប់សារពើពន្ធ ដោយមិនមានការផាកពិន័យ និងទោសទណ្ឌឡើយ។ ម្យ៉ាងវិញទៀតនិយោជិតដែលបំរើការជាមួយអង្គការសង្គមស៊ីវិលគួរត្រូវបានគិតគូរយ៉ាងយកចិត្តទុកដាក់ពីរាជរដ្ឋាភិបាលនូវអត្ថប្រយោជន៍នានា ដូចជាប្រាក់សោធននិវត្តន៍ ជាដើម និងការធានា និងពង្រឹងគុណភាពនៃសេវាគាំពារសង្គមផ្សេងៗដែលកំពុងដាក់អោយអនុវត្តដោយបេឡាជាតិរបបសន្តិសុខសង្គម។ល។
- ក្រសួងពាក់ព័ន្ធ និងអាជ្ញាធរនានា គួរមានការសម្របសម្រួល និងការឆ្លើយតបជាលក្ខណៈប្រព័ន្ធ និងដោយប្រើប្រាស់ប្រព័ន្ធបច្ចេកវិជ្ជាស្វ័យប្រវត្តិ (online) ដើម្បីកាត់បន្ថយភាពស្មុគ្រស្មាញនៃកិច្ចការរដ្ឋបាលដូចជាការចុះឈ្មោះ ការដាក់ជូនរបាយការណ៍ ការជូនដំណឹង ការទទួលស្គាល់ថ្នាក់ដឹកនាំ និងទទួលស្គាល់នៃការចុះអនុស្សរណៈយោគយល់សារឡើងវិញសម្រាប់អង្គការបរទេស ការធ្វើរបាយការណ៍ និងការជូនដំណឹងមុននឹងអនុវត្តសម្មភាព និងការប្រាស្រ័យទំនាក់ទំនងដើម្បីអនុវត្តកិច្ចសហប្រតិបត្តិការភាពជាដៃគូជាដើម។
- រាជរដ្ឋាភិបាល គួរធានាឲ្យមានការចូលរួមយ៉ាងពេញលេញពីសំណាក់សង្គមស៊ីវិល និងភាគីពាក់ព័ន្ធផ្សេងៗទៀត ទៅក្នុងដំណើរការនៃការបង្កើតនិងអនុវត្តច្បាប់ និងគោលនយោបាយនានា ជាពិសេសច្បាប់និងគោលនយោបាយដែលពាក់ព័ន្ធនឹងសង្គមស៊ីវិលតែម្តង។

<u>សំណើសុំសំខាន់ៗសំរាប់អង្គការសហប្រជាតិ និងដៃគូអភិវឌ្ឍន៍</u>៖

- គាំទ្រដល់ពង្រឹងយន្តការដែលមានស្រាប់ឲ្យមានគុណភាព និង ប្រសិទ្ធភាព ដូចជាក្រុមការងារបច្ចេកទេស (TWG) ក្របខណ្ឌគណនេយ្យភាពសង្គម (ISAF) និង បង្កើតយន្តការភាពជាដៃគូពហុភាគី (រដ្ឋាភិបាល សង្គមស៊ីវិល វិស័យឯកជន និងដៃគូអភិវឌ្ឍ) ស្របតាមគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព (SDG) និង ភាពជាដៃគូជាមួយរដ្ឋាភិបាលបើកទូលាយ (OGP)។
- បង្កើនការគាំទ្រទាំងផ្នែកហិរញ្ញប្បទាន និងបច្ចេកទេស ចំពោះគំនិតផ្តួចផ្តើមនានារបស់អង្គការសង្គមស៊ីវិលក្នុងគោលបំណងពង្រឹងសង្គមស៊ីវិល ជាពិសេសសពង្រឹងបណ្តាញអង្គការសង្គមស៊ីវិលនៅតាមបណ្

តាខេត្ត និងអង្គការសហគមន៍មូលដ្ឋាន ដើម្បីឲ្យពួកគេបន្តបំពេញតួនាទីសម្រាប់សម្រេចនូវ**ការអភិវឌ្ឍប្រកបដោយប្រជាធិបតេយ្យ និងចីរភាព** នៅកម្ពុជា។

- ធ្វើការជាដៃគូជាមួយរដ្ឋាភិបាលកម្ពុជា និងអ្នកពាក់ព័ន្ធប្រកបដោយបរិយាប័ន្នដើម្បីលើកកំពស់បរិយាកាសអំណោយផលដល់អង្គការសង្គមស៊ីវិលក្នុងការបំពេញការងាររបស់ខ្លួន។

**ឯកឧត្តម លោកជំទាវ អស់លោក លោកស្រីជាទីស្នេហា!**

ខ្ញុំបាទសង្ឃឹមថា សំណើខាងលើនេះនឹងត្រូវបានលើកយកមកពិភាក្សា និងឆ្លើយតបជាវិជ្ជមានពីសំណាក់រាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍ នៅក្នុងវេទិកានេះប្រកបដោយភាពជាដៃគូ និងការយោគយល់។

ជាថ្មីម្តងទៀត ខ្ញុំសូមបញ្ជាក់ថា សង្គមស៊ីវិលប្តេជ្ញាចិត្តនឹងដើរតួនាទីយ៉ាងសំខាន់ក្នុង**ការពិភាក្សាអំពីគោលនយោបាយនានា** ជាមួយរដ្ឋាភិបាល ចូលរួម**ការកសាងសមត្ថភាព និងការអភិវឌ្ឍធនធានមនុស្ស** ក៏ដូចជាចូលរួមក្នុងការ**ពង្រឹងភាពជាដៃគូពហុភាគី និងពង្រឹងអំណាចរបស់ប្រជាពលរដ្ឋ** និង**ការបំពេញតួនាទីផ្សេងៗ**ជាច្រើនទៀតសម្រាប់គាំទ្រដល់ការ**អភិវឌ្ឍប្រកបដោយប្រជាធិបតេយ្យ និងចីរភាព**សម្រាប់ប្រទេសកម្ពុជា។ ដើម្បីធានាការចូលរួមរបស់អង្គការសង្គមស៊ីវិលឲ្យមានភាពពេញលេញ និងប្រកបទៅដោយគុណភាព យើងខ្ញុំសង្ឃឹមយ៉ាងមុតមាំថា សង្គមស៊ីវិលនឹងទទួលបាននូវ**បរិយាកាសអំណោយផល លំហប្រជាធិបតេយ្យ កិច្ចសហប្រតិបត្តិការ** និងមានការអនុវត្តក្របខណ្ឌច្បាប់ ប្រកបដោយគតិយុត្តិ សុចរិត យុត្តិធម៌ និងមិនលំអៀង។

មុននឹងបញ្ចប់ ខ្ញុំសូមសម្តែងការកោតសរសើរ និងថ្លែងអំណរគុណចំពោះ**ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី** ពីក្រសួងមហាផ្ទៃ ក្រសួងពាក់ព័ន្ធនានា អង្គទូត និងដៃគូអភិវឌ្ឍទាំងអស់ដែលបានចូលរួមនៅក្នុងវេទិកាថ្ងៃនេះ។ ខ្ញុំសូមអរគុណដល់សហភាពអឺរ៉ុប អង្គការ ប្រេដហ្វដឺវើល អុកស្វាម និងម្ចាស់មូលនិធិនានាព្រមទាំងសមាជិក និងអង្គការដៃគូររបស់អង្គការCCC ដែលបានគាំទ្រទាំងមូលនិធិ និងស្មារតីដល់បេសកកម្មរបស់អង្គការCCC និងជាពិសេសវេទិកានេះតែម្តង។ ខ្ញុំក៏សូមអរគុណជាពិសេសដល់ថ្នាក់ដឹកនាំ និងបុគ្គលិកអង្គការ CCC ដែលបានរៀបចំនូវវេទិកាដ៏មានសារៈសំខាន់នេះ។

ខ្ញុំសូមគោរពជូនពរ **ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី ភ្ញៀវជាតិ និងអន្តរជាតិទាំងអស់**ឲ្យជួបតែពុទ្ធពរបួនប្រការ គឺអាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ និងសូមឲ្យវេទិកាថ្ងៃនេះសម្រេចបានជោគជ័យ។

សូមអរគុណ!